# គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

## Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL


ភ្នំពេញ, ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) មានកិត្តិយស សូមជម្រាបជូនដំណឹង និងគោរពអញ្ជើញដល់លោក លោកស្រី អ្នកនាង កញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ-អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ ខុមហ្វ្រែល នឹងមានរៀបចំវេទិកាយុវជនស្តីពី «**យុវជន និងសកម្មភាពការពារសិទ្ធិការងារនៅកន្លែងធ្វើការ**»។

វេទិកានេះត្រូវបានរៀបចំឡើង ក្រោមគម្រោងពង្រឹងសិទ្ធិអំណាចយុវជនទីប្រជុំជន។

**គោលបំណងនៃវេទិកា៖**

1. ផ្តល់ឱកាសដល់យុវជនក្នុងការលើកឡើង និងជជែកពីបញ្ហាដែលពួកគេបានជួបប្រទះ ព្រមទាំងកំណត់ពីបញ្ហាដែលត្រូវដោះស្រាយ។
2. បង្ហាញពីយន្តការក្នុងការតស៊ូមតិដើម្បីទាមទារសិទ្ធិការងារការទៅដល់កម្មករជាយុវជន។
3. ពិភាក្សា និងបង្ហាញពីរបៀបរៀបចំសកម្មភាព ដើម្បីដោះស្រាយបញ្ហា និងផ្សព្វផ្សាយពីរបៀបប្រើប្រាស់វេបសាយ "សម្លេងយុវជន" ។

**អ្នកចូលរួម** ៖ ក្រុមយុវជនកម្មកររោងចក្រ ១៥០នាក់ (៥០%ជាស្ត្រី)

**ទីកន្លែង** ៖ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
(ផ្ទះលេខ៩៣ ផ្លូវលេខ៥៩០ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ )

**កាលបរិច្ឆេទ** ៖ **ថ្ងៃអាទិត្យ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥** (ចាប់ពីម៉ោង ៧:៣០នាទីព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់)

**កិច្ចសហការណ៍** ៖ អង្គការខុមហ្វ្រែល សហព័ន្ធសហជីពកម្មករ ចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF) បណ្តាញពង្រឹងសិទ្ធិអំណាច ស្ត្រីវ័យក្មេងនៅកម្ពុជា(CYWEN) និងក្រុមនិស្សិតស្ម័គ្រចិត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខុមហ្វ្រែល សូមគោរពអញ្ជើញអស់លោក លោកស្រី អ្នកនាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ និងអន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ ទាំងអស់មេត្តាជ្រាប និងចូលរួមយកព័ត៌មានកុំបីខាន។


សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង
លោក **ជន ចាន់រ៉េន** (ជំនួយការគម្រោង)
ទូរស័ព្ទ ៖ ០១២ ២៧៥ ២៨៩


**ទស្សនៈវិស័យ** ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

**Vision** : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។